# អ្វីដែលអ្នកគួរយល់ដឹងអំពី
# ជំងឺរលាកថ្លើម ប្រភេទ A

## តើអ្វីជាជំងឺរលាកថ្លើមប្រភេទ A?

ជំងឺរលាកថ្លើមប្រភេទ A ជាជំងឺរលាកថ្លើមរយៈពេលខ្លី បង្កឡើងដោយមេរោគរលាកថ្លើមប្រភេទ A ។ ជំងឺនេះងាយនឹងឆ្លង ហើយវាប៉ះពាល់ដល់ដំណើការរបស់ថ្លើម ។

## រោគសញ្ញា និង អាការៈ

- គ្រុនក្តៅ
- ចំណង់អាហារចុះខ្សោយ
- អស់កំលាំង
- ចេញខាន់លឿង (ចេញលឿងលើស្បែក ឬ ភ្នែក)
- ទឹកនោមព័ណ៌ស្រអាប់ លាមកព័ណ៌ស្លេក ឬ មានរាករូស
- ក្អួតចង្អោរ

## អ្នកដែលងាយរងគ្រោះនឹងជំងឺរលាកថ្លើមប្រភេទ A

អ្នកដែលមិនបានចាក់ថ្នាំបង្ការមេរោគរលាកថ្លើមប្រភេទA ងាយនឹងរងគ្រោះនឹងការឆ្លងមេរោគនេះ ។ អ្នកដែលមានស្ថានភាពរស់នៅ ឬឥរិយាបថរស់នៅពិសេស ក៏ងាយនឹងឆ្លងជំងឺនេះផងដែរ ដូចជា៖

- អ្នកធ្វើដំណើរទៅក្រៅប្រទេស
- មនុស្សប្រុសដែលរួមភេទជាមួយមនុស្សប្រុស
- អ្នកដែលប្រើឬចាក់ថ្នាំញៀន
- អ្នកដែលមានការងារងាយនឹងមានការប៉ះពាល់
- អ្នកដែលមិនមានទីជំរក

## តើមេរោគរលាកថ្លើមប្រភេទ A ឆ្លងយ៉ាងដូចម្តេច ?

- មេរោគរលាកថ្លើមប្រភេទ A មានក្នុងលាមក ឬក្នុងឈាម អ្នកដែលមានផ្ទុកមេរោគនេះ ។ មេរោគនេះឆ្លង ទោះបីមានការប៉ះពាល់ក្នុងកំរិតដ៏តិចតួចបំផុតក៏ដោយ តាមរយៈ ៖
  - ការនៅជិតអ្នកដែលមានផ្ទុកមេរោគនេះ
  - ការបរិភោគចំណីអាហារដែលមានការប៉ពាល់នឹងមេរោគនេះ

## ការពារខ្លួនអ្នក និងអ្នកដ៏ទៃទៀត

**ចាក់ថ្នាំបង្ការ (វ៉ាក់សាំង)**
ត្រូវទៅចាក់ថ្នាំបង្ការជំងឺរលាកថ្លើមប្រភេទ A អោយបាន ពីរដូស

**ជៀសវាងធ្វើឬរៀបចំអាហារពេលកំពុងមានជំងឺ**
សូមកុំចម្អិនអាហារអោយអ្នកដ៏ទៃ ឬចែកអាហាររបស់អ្នកទៅអ្នកដ៏ទៃ នៅពេលអ្នកកំពុងឈឺ

**អនុវត្តន៍ការសំអាតដៃ**
លាងសំអាតដៃ ជាមួយសាប៊ូ និងទឹក

**តើអ្នកមានប៉ះពាល់ជាមួយអ្នកដែលមានជំងឺរលាកថ្លើមប្រភេទ A ឬទេ ?**
ត្រូវទាក់ទងទៅគ្រូពេទ្យប្រចាំខ្លួន បើអ្នកមានចេញអាការៈ ឬមានការប៉ះពាល់ជាមួយអ្នកដែលមានជំងឺរលាកថ្លើមប្រភេទ A ។

LONG BEACH HEALTH & HUMAN SERVICES

**សំរាប់ព័ត៌មានបន្ថែម៖**
562.570.4302| longbeach.gov/HepA